# ការកែលំអបច្ចេកទេសផលិតពូជត្រីប្រាធំ

## សេចក្តីផ្តើម

### ត្រីមេពូជ



ត្រីប្រាធំ (Pangasianodon hypopthalmus) មានប្រភពនៅក្នុងទន្លេមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា។ វាបានធ្វើការបំលាស់ទីគ្រប់ទីកន្លែងនៅតាមទន្លេ ស្ទឹង បឹងបួរ និងអាងស្តុកទឹកនានា ក្នុងបណ្តាប្រទេសអាស៊ី ។ ក្នុងធម្មជាតិត្រីប្រាធំ បានធ្វើការបន្តពូជនៅទន្លេមេគង្គលើចាប់ពីខេត្តក្រចេះ រហូតដល់ល្បាក់ខោនត្រង់ព្រំដែនកម្ពុជា-ឡាវ ។ ជារៀងរាល់ឆ្នាំនៅរដូវទឹកដំឡើងក្នុងខែមិថុនា និងកក្កដា កូនត្រីប្រាម្សៅបានអណ្តែតតាមចរន្តទឹកហូរពីទន្លេមេគង្គលើ ឆ្ពោះមកទន្លេមេគង្គក្រោម និងបានចរាចរចូលទៅតាមតំបន់ព្រៃលិចទឹកនានា ដើម្បីរកចំណី និងធំធាត់នៅទីនោះ ។ បន្ទាប់មកវាបានចរាចរចូលទៅក្នុងបឹងទន្លេសាប និងចុងក្រោយឆ្ពោះទៅទន្លេមេគង្គលើ ដើម្បីធ្វើការពងកូន ។ បច្ចុប្បន្នវិស័យវារីវប្បកម្មមានសន្ទុះរីកចម្រើនជាខ្លាំងជាហេតុធ្វើឲ្យតម្រូវការកូនត្រីពូជមានបរិមាណច្រើន ដូចនេះមជ្ឈមណ្ឌលមានតួនាទីសំខាន់ក្នុងការស្រាវជ្រាវ និងផលិតពូជត្រីឲ្យបានឆ្លើយតបនឹងតម្រូវការខាងលើ ។ ថ្មីៗនេះ មជ្ឈមណ្ឌលទទួលបានជោគជ័យក្នុងការបង្កាត់-ភ្ញាស់ពូជត្រីប្រាធំដោយសិប្បនិម្មិត ។



### ស្រះបំប៉នត្រីមេពូជ

## ១- ការថែបំប៉នត្រីមេពូជ

ស្រះត្រីមេពូជមានជម្រៅ ១.៥ម៉ែត្រ ស្តុកក្នុងដង់ស៊ីតេចំនួន ០.៥ គ.ក្រ ក្នុងមួយម៉ែត្រការ៉េ និងត្រូវប្តូរឲ្យបាន ៣០ ភាគរយ នៃទឹកស្រះជារៀងរាល់ ២ដងក្នុង១ខែ ។ ចំណីសម្រាប់ត្រីមេពូជមានពីរប្រភេទ ។ ប្រភេទទី១: មានប្រូតេអ៊ីន ៣៥ភាគរយ ឲ្យស៊ី

ចាប់ពី ខែធ្នូ ដល់ សីហា និងចំណីប្រភេទទី២ : មានប្រូតេអ៊ីន ២១ ភាគរយ ឲ្យស៊ីចាប់ពី ខែកញ្ញា ដល់ វិច្ឆិកា ។

## ២- ការរៀបចំស្រះផ្សាំកូនត្រី

ស្រះសម្រាប់ផ្សាំកូនត្រីគួរមានទំហំពី ៦០០-៥០០០ម៉ែត្រការ៉េ និងជម្រៅ ១.៥ម៉ែត្រ ។ មុនលែងកូនត្រី ត្រូវពង្រឹងស្រះបាចកំបោរក្នុងបរិមាណ ១០០ក្រាម ក្នុង១ម៉ែត្រការ៉េ ។ មុនចាក់អ័រម៉ូនត្រីមេពូជ ១ ថ្ងៃ ត្រូវបញ្ចូលទឹកក្នុងស្រះ ផ្សាំកូនត្រីឲ្យបាន ៨០ភាគរយ បន្ទាប់មកដាក់ជី ដេអាប៉េ ចំនួន ១០០ ក្រាម កន្ទក់ ៨ក្រាម ម្សៅត្រី ៤ក្រាម និងម្សៅសន្ដែកសៀង ចំនួន ៤ក្រាម ក្នុង ១ម៉ែត្រការ៉េ ដោយព្រាចលើផ្ទៃស្រះ ។ កូនត្រីម្សៅនឹងលែងចូលស្រះ បន្ទាប់ពីដាក់ជីបានរយៈពេល ២-៣ ថ្ងៃ ។



ការជ្រើសរើសត្រីមេពូជ

## ៣- ការបង្កាត់ - ភ្ញាស់តីប្រាដោយសិប្បនិម្មិត

### ៣-១ ការជ្រើសរើសត្រីមេពូជ

ត្រីមេត្រូវមានពោះធំ ទន់ និងគ្រាប់ពងមានពណ៌សស្រអាប់ និងមានទំហំប៉ុនៗគ្នា រីឯត្រីឈ្មោលវិញគ្រាន់តែច្បូតថ្នមៗ នៅលើរន្ធបន្តពូជឃើញមានចេញស្ពែមពណ៌ស គឺយើងអាចជ្រើសរើសយកសម្រាប់ធ្វើការបង្កាត់បាន ។

### ៣-២ ការចាក់អ័រម៉ូន



ការចាក់អ័រម៉ូនត្រីពូជ

**- ត្រីមេ :**

ប្រើអ័រម៉ូន HCG ដំបូងចាក់ក្នុងបរិមាណ ៣០០ និង ៥០០ UI/គ.ក្រ ក្នុងចន្លោះរយៈពេល ២៤ ម៉ោង សម្រាប់ការចាក់លើកទី ១ និងទី ២ និងចាក់លើកទី ៣ មានរយៈពេល ១០ ម៉ោង (ក្រោយចាក់លើកទី ២) ក្នុងបរិមាណ ៣០០០ UI/គ.ក្រ ។ ក្រោយចាក់លើទី ៣ បានរយៈពេល ៧ ម៉ោងយើងពិនិត្យ

ដំណាក់កាលច្បូតពងត្រីដោយសង្កត់ថ្នមៗនៅផ្នែកពោះរហូតដល់រន្ធបន្តពូជ ។ បើសិនជាមិនទាន់ដល់ដំណាក់កាលច្បូតទេ ។ យើងត្រូវចាក់អ័រម៉ូនបន្ថែមលើកទី ៤ និងទី ៥ ទៀតក្នុងបរិមាណ ១៥០០ UI/ គ.ក្រ ចន្លោះពេល ៤ ម៉ោង ។

- ត្រីឈ្មោល :

សម្រាប់ត្រីឈ្មោលចាក់តែ ១លើក ក្នុងបរិមាណ ១០០០ UI/គ.ក្រ គឺចាក់នៅពេលចាក់ត្រីលើកទី៣។



ការច្បូតយកស្ពែមពីត្រីឈ្មោល

### ៣-៣ ការច្បូតយកគ្រាប់ពង និងការផ្សំកំណើត

#### - ការច្បូតយកគ្រាប់ពង :

យើងច្បូតយកគ្រាប់ពង ដោយច្បូតនៅផ្នែកពោះរហូតដល់រន្ធបន្តពូជ ។ នៅពេលច្បូតត្រីមេរួចយើងត្រូវចាប់ត្រីឈ្មោលជាបន្ទាន់ ដោយជូតសំអាតទឹក រួចច្បូតយកស្ពែមលាយជាមួយគ្រាប់ពង ។

#### - ការផ្សំកំណើត :

ការផ្សំកំណើតដោយវិធីសាស្ត្រស្ងួត ។ ពងត្រីដែលច្បូតរួចត្រូវបានដាក់ក្នុងផុងជ័រស្អាតគ្មានទឹក ។ បន្ទាប់មកច្បូតយកស្ពែមត្រីឈ្មោលដាក់រាយប៉ាយទៅលើគ្រាប់ពង (ឈ្មោល២) រួចកូរដោយស្លាបមាន់ ។ ភ្លាមៗនោះយើងចាក់ទឹកចូលបន្តិចដោយបន្តការកូររយៈពេល ១នាទី ដើម្បីឲ្យគ្រាប់ពងផ្សំកំណើតបានល្អ ។

បន្ទាប់មកត្រូវបន្ថែមទឹកទៀត ដើម្បីលាងជាតិរំអិល ឬស្ពែមដែលនៅសល់ចេញពីគ្រាប់ពង ។ បន្ទាប់ពីទទួលបានគ្រាប់ពងផ្សំកំណើតរួច យើងត្រូវបំបាត់ជាតិស្អិតរបស់គ្រាប់ពងដោយទឹកម្សៅដីឥដ្ឋ ។

ប្រព័ន្ធភ្ញាស់គ្រាប់ពង

## ៣-៤ ការភ្ញាស់ពងត្រីប្រា :



បន្ទាប់ពីបំបាត់ជាតិស្អិតរួច យើងដួសគ្រាប់ពងដាក់ភ្ញាស់ក្នុងបំពង់កែវ ដែលបំពង់កែវនីមួយៗ អាចដាក់គ្រាប់ពងចំណុះ ៥០០ក្រាម ។ គ្រាប់ពងដែលផ្សំកំណើតល្អ មានរាងមូលទំហំតូចមានពណ៌លឿងថ្លា និងមានលក្ខណៈស្អិតពេលប៉ះជាមួយទឹក ។ ពងត្រីញាស់ក្នុងរយៈពេល ២០ម៉ោង បន្ទាប់ពីផ្សំកំណើតនៅសីតុណ្ហភាពពី ២៦-៣០ អង្សារសេ ។ កូត្រីញាស់ទាំងស្រុងមានរយៈពេល ២៨ម៉ោង បន្ទាប់ពី -ផ្សំកំណើត :

កូនត្រីក្រោយញាស់រយៈពេល ២៤ម៉ោង ប្រភពពីMimid , M.A., et al. (2007)




កូនត្រីទើបញាស់មានដងខ្លួនប្រវែង ៤មីល្លីម៉ែត្រ ភ្នែកមិនទាន់មានរូបរាងច្បាស់លាស់ មាត់ និងរន្ធបញ្ចេញចោលមិនទាន់បើក ។ ក្រោយញាស់រយៈពេល ១៦ម៉ោង កូនត្រីចាប់ផ្តើមបើកមាត់មានរន្ធបញ្ចេញចោល និងមានធ្មេញ (រូបទី៦) ។ បន្ទាប់មកប្រដាប់រំលាយអាហារបានដំណើរការ និងមានតួនាទីសំខាន់ដូចនេះការផ្តល់ចំណីដំបូងត្រូវចាប់ផ្តើមនៅរយៈពេល ៣០ម៉ោង ក្រោយញាស់ ។

## ៤- ការផ្សាំកូនត្រីប្រាម្សៅ :

កូនត្រីប្រាម្សៅត្រូវលែងចូលស្រះឲ្យបានមុនរយៈពេល ៣០ម៉ោង ក្រោយញាស់ចៀសវាងដំណាក់កាលកូនត្រីស៊ីគ្នា ។ ដង់ស៊ីតេស្តុកពី ៣០០-៥០០ ក្នុងមួយម៉ែត្រការ៉េ ។ ក្រោយលែងកូនត្រីរួចត្រូវបញ្ចូលទឹកបន្ថែម ២០ភាគរយ ។

- **ការផ្តល់ចំណី :**

ចំណីសម្រាប់កូនត្រីម្សៅមាន : ចៃទឹករស់ និងម្សៅទឹកដោះគោ ឲ្យស៊ីពីថ្ងៃទី ១ ដល់ ៧ ។ នៅថ្ងៃទី ៨ ត្រូវបង្វឹកកូនត្រីឲ្យស៊ីចំណីគ្រាន់តែជាប្រភេទម្សៅដោយលាយជាមួយចៃទឹកក្លាសេឲ្យស៊ីរហូតដល់ថ្ងៃទី ១៣ ។

ថ្ងៃទី ១៤ ផ្តល់ចំណីទំហំ ០.៤ មីល្លីម៉ែត្រជាប្រភេទចំណីអណ្តែតមានប្រូតេអ៊ីន ៤០ភាគរយ ។ នៅថ្ងៃទី ២១ កូនត្រីចូលស៊ីចំណី ១កន្លែង យើងផ្តល់ចំណីទំហំ ០.៦ ០.៨ និង ១.០ មីល្លីម៉ែត្រ រហូតក្លាយជាកូនត្រីពូជនៅថ្ងៃទី ៤០ ឬ ថ្ងៃទី ៤៥ ។

- **ត្រួតពិនិត្យជំងឺ និងសត្វល្អិត :**

ពេលសង្កេតឃើញមានកូនត្រីងាប់អណ្តែតនៅលើផ្ទៃទឹក និងឃើញមានស្បែកដាច់រលាត់ ឬមានពណ៌ក្រហមនៅផ្នែកខ្នង ឬនៅព្រុយកន្ទុយ យើងអាចកំណត់បានគឺបង្កដោយពពួកបាក់តេរីប្រភេទ Vibrio និង Aeromonas យើងប្រើថ្នាំប្រភេទ Oxytetracycline ក្នុងបរិមាណ ៥០ម.ក្រ/គ.ក្រ នៃទម្ងន់ត្រី លាយជាមួយចំណីដែលត្រូវផ្តល់ឲ្យកូនត្រី ។ នៅពេលជាមួយគ្នានោះ យើងអាចប្រើ Zeolite (ដូចសិលាគ្រាប់តូចៗ) ក្នុងបរិមាណ ១គ.ក្រ ក្នុងមួយម៉ែត្រការ៉េ ទៅលើផ្ទៃស្រះ ដើម្បីបង្កើនគុណភាពទឹក និងដីបាតស្រះ ។ ម្យ៉ាងទៀតត្រូវយកចិត្តទុកដាក់កំចាត់សត្វចង្រៃផ្សេងៗ ដើម្បីកូនត្រីមានអត្រាគង់វង្សខ្ពស់៕

រៀបរៀងដោយ: លោក សំ ណារិទ្ធ អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប